# របាយការណ៍
# ឯកឧត្តមបណ្ឌិត ចន ណារិទ្ធ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម
# ថ្លែងក្នុង
# សន្និសីទជាតិស្តីពី "សមិទ្ធផលនៃប្រព័ន្ធគាំពារសង្គមកម្ពុជា"

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤

- ជាបឋម ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់គោរពជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម
- សូមគោរព **ឯកឧត្តមទេសរដ្ឋមន្ត្រី, ឯកឧត្តមរដ្ឋមន្ត្រី, ឯកឧត្តមរដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី**
- ឯកឧត្តម លោកជំទាវ អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម និងលោកជំទាវ ឯកឧត្តម ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម, ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន តំណាងដៃគូអភិវឌ្ឍន៍ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ!

ជាមួយនឹងក្តីសោមនស្សយ៉ាងក្រៃលែង, ខ្ញុំសូមគោរព និងស្វាគមន៍វត្តមានដ៏ខ្ពង់ខ្ពស់របស់ គណៈអធិបតី ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ក្នុងសន្និសីទជាតិ ស្តីពី "សមិទ្ធផលនៃប្រព័ន្ធគាំពារសង្គមកម្ពុជា" នាថ្ងៃនេះ។

ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលចំណាយពេលដ៏មមាញឹក និងមានតម្លៃ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងសន្និសីទជាតិនេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណ និងសម្តែងនូវគារវកិច្ច និងការស្វាគមន៍យ៉ាងកក់ក្តៅផងដែរ ចំពោះវត្តមានរបស់ **ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី** ដែលជាថ្នាក់ដឹកនាំតំណាងក្រសួង-ស្ថាប័ន, តំណាងនិយោជក, និយោជិត, ដៃគូអភិវឌ្ឍន៍, អង្គការសង្គមស៊ីវិល, និងភាគីពាក់ព័ន្ធនានា ដែលបានចូលរួមក្នុងសន្និសីទជាតិដ៏មានសារៈសំខាន់នេះ ទាំងដោយផ្ទាល់នៅទីនេះ និងតាមប្រព័ន្ធអនឡាញ។

*- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

*- ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី!*

សន្និសីទជាតិនៅថ្ងៃនេះ មានគោលបំណងបង្ហាញ និងផ្សព្វផ្សាយពីវឌ្ឍនភាព និងសមិទ្ធផលចម្បងៗនៃប្រព័ន្ធគាំពារសង្គមកម្ពុជា ដែលសម្រេចបាន នាពេលកន្លងមក ពិសេសចាប់តាំងពីការដាក់ឱ្យអនុវត្ត **"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥"** និងវត្តមានរបស់ **"ក្រុមប្រឹក្សាជាតិគាំពារសង្គម"** កាលពីឆ្នាំ២០១៧ រួមជាមួយកិច្ចសហការយ៉ាងល្អរវាងក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់។ ការបំពេញការងាររួមគ្នានេះ បានរួមចំណែកធ្វើឱ្យប្រព័ន្ធគាំពារសង្គមកម្ពុជារឹងមាំ, មានភាពសមាហរណៃ, សង្គតិភាព និងប្រសិទ្ធភាព ក្នុងការផ្តល់ការគាំពារជូនពលរដ្ឋកាន់តែប្រសើរ ដោយឈរលើស្មារតី **"មិនបោះបង់ពលរដ្ឋណាម្នាក់"**។

ដើម្បីបង្ហាញច្បាស់អំពីសមិទ្ធផលនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា, ខ្ញុំសូមយកឱកាសនេះ គោរពរាយការណ៍អំពីវឌ្ឍនភាព និងការសម្រេចបានសំខាន់ៗ ដោយចែកជា ៣ ផ្នែកគឺ៖ ១). ការកសាងប្រព័ន្ធ, ២).ការដាក់ចេញ និងការពង្រីកវិសាលភាពកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម, និង ៣).ការឆ្លើយតបនឹងគ្រោះអាសន្ន។

ក្រោមការដឹកនាំ និងតម្រង់ទិសរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម និងដូចមានកំណត់ក្នុង "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥", ប្រព័ន្ធគាំពារសង្គមកម្ពុជា បានក្លាយជាប្រព័ន្ធមួយរឹងមាំ ដែលមានវិសាលភាពធំជាងមុន និងអាចបត់បែនឆ្លើយតបនឹងគ្រោះអាសន្ននានា។ ទាំងនេះ ជាលទ្ធផលនៃការវិនិយោគរបស់រាជរដ្ឋាភិបាលលើការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព និងចីរភាព។

ដើម្បីកសាងប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈរឹងមាំដូចសព្វថ្ងៃនេះ, រាជរដ្ឋាភិបាលបានផ្តោតលើការរៀបចំ និងដាក់ចេញបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា សម្រាប់ធ្វើស្ថាប័នូបនីយកម្ម និងអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម។ លើសពីនេះ, រាជរដ្ឋាភិបាល

បានដាក់ឱ្យអនុវត្តឯកសារក្របខណ្ឌ, ផែនទីបង្ហាញផ្លូវ, យុទ្ធសាស្ត្រ, និងគោលការណ៍ណែនាំសំខាន់ៗ ពាក់ព័ន្ធនឹងការជំរុញការអនុវត្តកម្មវិធីជាតិជំនួយសង្គម, របបសន្តិសុខសង្គម និងអន្តរាគមន៍គាំពារសង្គមជាបន្តបន្ទាប់ ដែលឯកសារទាំងនេះរួមមាន៖

១. ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ ២០២៤-២០៣៥,

២. គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន,

៣. គោលការណ៍ណែនាំស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ,

៤. ផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម,

៥. គោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន,

៦. យុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយគាំពារសង្គមកម្ពុជា, និង

៧.សៀវភៅណែនាំស្តីពីយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ជាដើម។

ជាមួយគ្នានេះ, យន្តការស្ថាប័នក្នុងប្រព័ន្ធគាំពារសង្គមក៏ត្រូវបានកែទម្រង់, ពង្រឹង និងពង្រីកមុខងារ ដើម្បីធានាថា ការចាត់ចែង និងគ្រប់គ្រងកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនានា ជាពិសេសការផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋគោលដៅ ត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដែលក្នុងនោះស្ថាប័នចំនួន ២ ត្រូវបានកែទម្រង់ គឺ **បេឡាជាតិរបបសន្តិសុខសង្គម**(ប.ស.ស.) ត្រូវបានកែទម្រង់ និងប្តូរឈ្មោះដោយរៀបចំឡើងវិញមកជា **បេឡាជាតិសន្តិសុខសង្គម** កាលពីឆ្នាំ ២០១៩ ដើម្បីឆ្លើយតបនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើត និងដាក់ឱ្យដំណើរការស្ថាប័នប្រតិបត្តិករទោលសម្រាប់ប្រព័ន្ធសន្តិសុខសង្គម។ **ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល** ក៏ត្រូវបានកែទម្រង់ និងប្តូរឈ្មោះមកជា **ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ** កាលពីឆ្នាំ២០២៣ ដើម្បីឱ្យក្លាយជាស្ថាប័នមានឯករាជ្យភាព ក្នុងការបំពេញមុខងារបញ្ជាក់ចំណាយ លើរាល់ការស្នើសុំទូទាត់ថ្លៃសេវាថែទាំសុខភាព របស់មូលនិធិសមធម៌សុខាភិបាល និងពង្រីកមុខងារទៅដល់ការបញ្ជាក់ចំណាយសម្រាប់សេវាវេជ្ជសាស្ត្រនៃរបបសន្តិសុខសង្គម ផងដែរ។

ព្រមជាមួយគ្នានោះ, រាជរដ្ឋាភិបាលបានបង្កើត និងដាក់ឱ្យដំណើរការស្ថាប័នថ្មីចំនួន ២ បន្ថែមទៀតរួមមាន៖ **និយ័តករសន្តិសុខសង្គម (ន.ស.ស.)** ត្រូវបានបង្កើតឡើងកាលពីឆ្នាំ ២០២១ ដើម្បីបំពេញមុខងារធ្វើនិយ័តកម្ម និងត្រួតពិនិត្យរាល់ប្រតិបត្តិការ នៃរបបសន្តិសុខ

សង្គម សំដៅធានានូវការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងមានភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងកាលពីឆ្នាំ២០២២, **មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.)** ក៏ត្រូវបានបង្កើតឡើង ក្នុងគោលដៅឆ្លើយតបនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើសមាហរណកម្មការគ្រប់គ្រង និងចាត់ចែងកម្មវិធីជាតិជំនួយសង្គមឱ្យស្ថិតនៅក្រោមប្រតិបត្តិករតែមួយ។

បន្ថែមលើនេះ, រាជរដ្ឋាភិបាលក៏បានរៀបចំបង្កើត និងចាប់ផ្តើមដាក់ឱ្យដំណើរការប្រព័ន្ធគាំពារសង្គមឌីជីថល ដែលសម្រួលដល់ប្រតិបត្តិការកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ចាប់តាំងពីកម្រិតរដ្ឋបាលឃុំ សង្កាត់ ដល់ថ្នាក់ជាតិ ដែលបច្ចុប្បន្ន កំពុងត្រូវបានតភ្ជាប់ និងឆ្លើយឆ្លងគ្នាទៅវិញទៅមក ក្នុងគោលដៅបង្កើនប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, និងតម្លាភាព ក្នុងការគ្រប់គ្រង និងចាត់ចែងការផ្តល់អត្ថប្រយោជន៍គាំពារសង្គមជូនពលរដ្ឋគោលដៅ។ យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ក៏ត្រូវបានដាក់ឱ្យដំណើរការចាប់តាំងពីចុងឆ្នាំ២០២០ ផងដែរ ដើម្បីពិនិត្យវឌ្ឍនភាព និងតម្រូវការកែសម្រួលការអនុវត្តការងារឱ្យបានទាន់ពេល សំដៅពង្រឹងប្រសិទ្ធភាព និងអាចសម្រេចបាននូវគោលដៅដូចគ្រោងទុក ដែលកិច្ចការនេះ ត្រូវបានរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ចាត់ទុកថាមានសារៈសំខាន់ ក្នុងការវាស់វែងប្រសិទ្ធភាព និងលទ្ធផលនៃផែនការនីមួយៗដែលបានដាក់ចេញ។

ការកសាងប្រព័ន្ធមួយដែលមានលក្ខណៈច្បាស់លាស់នេះ បានផ្តល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំ និងជាកាតាលិករដ៏សំខាន់ ដែលធ្វើឱ្យរាជរដ្ឋាភិបាលអាចដាក់ចេញ និងពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម បានយ៉ាងទូលំទូលាយនាពេលកន្លងមក និងដែលស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដោយសង្កត់ធ្ងន់ថា ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ត្រូវឈរលើអភិក្រម **«ពង្រឹងប្រព័ន្ធ ដើម្បីពង្រីកការគ្របដណ្តប់»**។

*- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី!*
*- ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី!*

គិតចាប់តាំងពីឆ្នាំ២០១៧ មក, រាជរដ្ឋាភិបាលបាន និងកំពុងពង្រីកវិសាលភាពប្រព័ន្ធគាំពារសង្គម ដើម្បីផ្តល់ការគាំពារដល់ពលរដ្ឋ តាមរយៈការពង្រីកវិសាលភាព

កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលមានស្រាប់ និងការដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមថ្មីៗ ជាបន្តបន្ទាប់ដូចខាងក្រោម៖

**ក្នុងទិដ្ឋភាពជំនួយសង្គម៖**

កាលពីឆ្នាំ២០១៧, កម្មវិធីជំនួយសង្គមមានតែ ២ ប៉ុណ្ណោះ និងមានវិសាលភាពគ្របដណ្តប់ពលរដ្ឋបានតែចំនួនប្រមាណ **២ លាននាក់** ដោយចំណាយថវិកាជាតិជាង **៩៣ ប៊ីលានរៀល** ឬសមមូលនឹង **២៣,៤ លានដុល្លារអាម៉េរិក** ក្នុងមួយឆ្នាំ។ កម្មវិធីជំនួយសង្គមទាំងពីរនេះ គឺ ៖

១). **កម្មវិធីអាហារូបករណ៍សិស្សក្រីក្រ៖** បានផ្តល់ប្រាក់ឧបត្ថម្ភដល់សិស្សចំនួនប្រមាណ **១៦ ម៉ឺននាក់** មកពីគ្រួសារក្រីក្រ និងបានសិក្សានៅសាលារៀនរដ្ឋ។

២). **មូលនិធិសមធម៌សុខាភិបាល៖** បានផ្តល់ការថែទាំសុខភាពដល់ពលរដ្ឋក្រីក្រប្រមាណ **៥០ ម៉ឺនគ្រួសារ** មានសមាជិកចំនួនប្រមាណ **២ លាននាក់** ដោយរដ្ឋជាអ្នកបង់ថ្លៃជំនួស ។

រហូតមកដល់២០២៤ នេះ, កម្មវិធីជាតិជំនួយសង្គមមានចំនួន ៨ ដែលមានវិសាលភាពគ្របដណ្តប់លើពលរដ្ឋសរុបចំនួន **១,២ លានគ្រួសារ** ដែលមានសមាជិកចំនួនជាង **៤,៨ លាននាក់** (ស្មើនឹងប្រមាណ ២៨% នៃពលរដ្ឋសរុប) ដោយចំណាយថវិកាជាតិបានកើនឡើងដល់ **១ ១៣៩,៧ ប៊ីលានរៀល** ឬស្មើនឹង **២៨៥ លានដុល្លារអាម៉េរិក** សម្រាប់ឆ្នាំ២០២៤ ដែលក្នុងនោះមាន៖

១). **កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** ដែលត្រូវបានបង្កើត និងដាក់ឱ្យអនុវត្តចាប់ពីខែមេសា ឆ្នាំ២០២៤ កន្លងមក។ កម្មវិធីនេះ ជាការធ្វើសមាហរណកម្មកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដែលមានស្រាប់ និងបង្កើតកម្មវិធីថ្មីចំនួន ៤ គឺ៖

- **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ** ដែលបានដាក់ឱ្យអនុវត្ត កាលពីឆ្នាំ២០១៩ និងបានពង្រីកវិសាលភាពជាបន្តបន្ទាប់ព្រមទាំងបានដំឡើងកម្រិតប្រាក់ឧបត្ថម្ភទ្វេដង ដោយគិតមកដល់បច្ចុប្បន្នមានអ្នកទទួលផលសរុបចំនួនប្រមាណ **៣៧ ម៉ឺននាក់**។
- **កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ** ដែលបានពង្រីកវិសាលភាពជាបន្តបន្ទាប់ដោយពង្រីកការអនុវត្តសម្រាប់ទាំងថ្នាក់បឋមសិក្សា និងថ្នាក់មធ្យមសិក្សា ដោយមានសិស្សក្រីក្រទទួលផលសរុបចំនួនជាង **២៦ ម៉ឺននាក់** សម្រាប់

ឆ្នាំ២០២៤ ហើយកម្មវិធីនេះ នឹងត្រូវពង្រីកវិសាលភាពបន្ថែមទៀត ទៅជាការផ្តល់ដល់ "សិស្សមកពីគ្រួសារក្រីក្រទាំងអស់ នៅទូទាំងប្រទេស" នៅឆ្នាំ២០២៥ ខាងមុខ ដែលតាមការប៉ាន់ស្មាន នឹងមានចំនួន ប្រមាណ **៩៥ ម៉ឺននាក់**។

- **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព** ដែលបានពង្រីកវិសាលភាពដល់ជនមានពិការភាពមកពីគ្រួសារក្រីក្រទាំងអស់ទូទាំងប្រទេស ដែលកំពុងស្ថិតក្នុងដំណាក់កាលកំណត់អត្តសញ្ញាណជាមួយនឹងវិធីសាស្ត្រគ្រប់ជ្រុងជ្រោយតាមគំរូសង្គម និងសិទ្ធជាមូលដ្ឋាន និងដែលបច្ចុប្បន្នមានអ្នកចាប់ផ្តើមទទួលផលចំនួន **២២ ០៤៤ នាក់**។
- **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា** ដែលត្រូវបានបង្កើតឡើងថ្មីក្នុងកញ្ចប់គ្រួសារ ដើម្បីផ្តល់ប្រាក់ឧបត្ថម្ភដល់ជនចាស់ជរាមកពីគ្រួសារក្រីក្រទូទាំងប្រទេសដែលបច្ចុប្បន្នមានអ្នកទទួលផលចំនួន **២៩៩ ១៥៥ នាក់**។

ជាមួយគ្នានេះ, ក្នុងកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ក៏មានការឧបត្ថម្ភគោលសម្រាប់គ្រួសារក្រីក្រទាំងអស់ ដែលបច្ចុប្បន្នមានជាង **៦១ម៉ឺន** គ្រួសារបានទទួលផល និងការឧបត្ថម្ភសមាជិកដែលរស់នៅជាមួយមេរោគ/ជំងឺអេដស៍ ចំនួន **១ ៩៤៧ នាក់** ផងដែរ។

២). បន្ថែមលើកញ្ចប់គ្រួសារនេះ, **កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍** ក៏ត្រូវបានដាក់ឱ្យអនុវត្តជាកម្មវិធីជាតិជំនួយសង្គមកាលពីដើមឆ្នាំ២០២០ ក្នុងគោលបំណងលើកកម្ពស់អាហារូបត្ថម្ភ និងការសិក្សារបស់កុមារ ក្នុងតំបន់មានភាពក្រីក្រ និងភាពងាយរងគ្រោះខ្ពស់ ដោយចូលរួមលើកកម្ពស់សេដ្ឋកិច្ចសហគមន៍ផងដែរ។ កម្មវិធីនេះបានពង្រីកវិសាលភាពជាបន្តបន្ទាប់ ដែលបច្ចុប្បន្ន មានសាលារៀនអនុវត្តកម្មវិធីនេះ សរុបមានចំនួន **១ ១១៤ សាលា** និងសិស្សទទួលផលប្រមាណ **៣០ម៉ឺននាក់** ដែលក្នុងនោះរាជរដ្ឋាភិបាលបានទទួលយកសាលាគោលដៅពីដៃគូអភិវឌ្ឍន៍ចំនួន **៥៥៣ សាលា** ក្នុងខេត្តចំនួន ១០ និងមានសិស្សទទួលផលជាង **១៥ម៉ឺននាក់**។

៣). **កម្មវិធីជំនួយសង្គមផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈជូនយុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ** ត្រូវបានដាក់ឱ្យអនុវត្ត ដោយគិតត្រឹមខែតុលា ឆ្នាំ២០២៤ មានយុវជនបានចុះឈ្មោះចូលរៀនចំនួនប្រមាណជិត **៧ ម៉ឺននាក់** ក្នុងនោះ ក្រុមគោលដៅជាយុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យមានចំនួនជាង **២ម៉ឺននាក់**។

៤). **មូលនិធិសមធម៌សុខាភិបាល** ត្រូវបានពង្រីកវិសាលភាពដល់ក្រុមពលរដ្ឋគោលដៅផ្សេងទៀត រួមមានពលរដ្ឋមកពីគ្រួសារងាយរងហានិភ័យ, កម្មករក្រៅប្រព័ន្ធ, អ្នកជាក់ស៊ីក្លូ, កីឡាករជម្រើសជាតិ, ក្រុមគ្រួសារជនពលីមរណៈ, បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងបុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្សេងទៀត បន្ថែមលើ ពលរដ្ឋក្រីក្រដែលមានបណ្ណសមធម៌ ដែលជារួមពលរដ្ឋប្រមាណ **៤,៨ លាននាក់** កំពុងទទួលបានការថែទាំសុខភាព នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ឬមន្ទីរពេទ្យរដ្ឋដោយរដ្ឋជាអ្នកបង់ថ្លៃជំនួស។

៥). **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំសម្រាប់សមាជិក ប.ស.ស. ជាស្ត្រី** ត្រូវបានចាប់ផ្តើមអនុវត្តដំបូងក្នុងឆ្នាំ២០១៨ ដោយផ្តល់ការឧបត្ថម្ភសាច់ប្រាក់ជូនកម្មករនិយោជិតជាស្ត្រីនៅពេលសម្រាល។ ចាប់ពីខែសីហា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានដំឡើងប្រាក់ឧបត្ថម្ភ ព្រមទាំងផ្តល់សេវាសុខាភិបាលបន្ថែមទាំង ក្នុងអំឡុង មានផ្ទៃពោះ និងក្រោយពេលសម្រាលរហូតដល់កុមារអាយុ ២ឆ្នាំ ហើយបានពង្រីកវិសាលភាពដល់មន្ត្រីរាជការ, មន្ត្រីកម្មសិក្សា, និងមន្ត្រីជាប់កិច្ចសន្យា ជាស្ត្រីផងដែរ។ គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤, ស្ត្រី និងកុមារសរុបប្រមាណ **៧៧ ម៉ឺននាក់** បានទទួលអត្ថប្រយោជន៍ពីកម្មវិធីនេះ។

### ដោយឡែកក្នុងទិដ្ឋភាពសន្តិសុខសង្គម៖

នៅឆ្នាំ២០១៧, របបសន្តិសុខសង្គមមានចំនួន ៣ ប៉ុន្តែវិសាលភាពនៅមានកម្រិត ដោយបានគ្របដណ្តប់ពលរដ្ឋត្រឹម **១,២៦ លាននាក់** និងចំណាយថវិកាសរុបចំនួនប្រមាណ **៧២៩ ប៊ីលានរៀល** ឬសមមូលនឹង **១៨២ លានដុល្លារអាមេរិក** ដែលក្នុងនោះមាន៖

១). **របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព** ត្រូវបានបង្កើតឡើងដំបូងសម្រាប់តែកម្មករនិយោជិត ក្នុងគោលបំណងលើកទឹកចិត្ត និងផ្តល់តាវលិកផ្នែកថែទាំសុខភាព ដើម្បីឱ្យពួកគាត់មានសុខភាពល្អអាចបន្តបំពេញការងារ និងជួយកាត់បន្ថយហានិភ័យផ្នែកហិរញ្ញវត្ថុ នៅពេលធ្លាក់ខ្លួនឈឺ ។

២). **របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ** ត្រូវបានបង្កើតឡើងដំបូងសម្រាប់តែកម្មករនិយោជិត ក្នុងគោលបំណងផ្តល់ការធានាលើគ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងពេលបំពេញការងារ ទាំងនៅកន្លែងធ្វើការផ្ទាល់

ការធ្វើដំណើរទៅ និងត្រឡប់មកពីកន្លែងការងារ និងជំងឺវិជ្ជាជីវៈ ដែលកាលពីឆ្នាំ ២០១៧ របបទាំង២នេះ មានសមាជិកប្រមាណ **១,១ លាននាក់** ។

៣). **របបសន្តិសុខសង្គមផ្នែកប្រាក់សោធន** ត្រូវបានបង្កើតឡើង ក្នុងគោលបំណង ធានាសន្តិសុខ និងស្ថិរភាពប្រាក់ចំណូលនៅពេលចូលនិវត្តន៍ និងរួមចំណែក ការពារសិទ្ធិសេរីភាពរបស់មនុស្សវ័យចាស់ ដែលកាលពីឆ្នាំ២០១៧ មានតែ សម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដោយរដ្ឋជាអ្នករ៉ាប់រង ចំណាយថវិកាចំនួនប្រមាណ **១៧៣ លានដុល្លារ** សម្រាប់និវត្តជនចំនួន **១០៨ ពាន់នាក់**។

បច្ចុប្បន្នប្រព័ន្ធសន្តិសុខសង្គមបានពង្រីកវិសាលភាព ដោយគិតត្រឹមឆ្នាំ២០២៤ នេះ បានគ្របដណ្តប់លើប្រជាពលរដ្ឋសរុបប្រមាណ **២,៥ លាននាក់** ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន (ដែលបានកើនឡើងទ្វេដង) ហើយបានចំណាយថវិកាសរុបចំនួន ប្រមាណ **២ ២៩៦ ប៊ីលានរៀល** ឬសមមូលនឹង **៥៧៤ លានដុល្លារអាម៉េរិក** ដោយថវិកាជាតិ ចំនួន **៤០៦ លានដុល្លារ** និងថវិកាភាគទានប្រមាណ **១៦៨ លានដុល្លារ** ក្នុងមួយឆ្នាំ ដែល សម្រេចបានសមិទ្ធផលដូចខាងក្រោម៖

១). **របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព** បានពង្រីកវិសាលភាពជាបន្តបន្ទាប់ ដល់បុគ្គលក្នុងវិស័យសាធារណៈ, បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុក បន្ថែមលើកម្មករនិយោជិត ដែលបច្ចុប្បន្ន សមាជិកសកម្មសរុបមានចំនួន **២,៥៣ លាននាក់** ក្នុងនោះ កម្មករនិយោជិតចំនួន **១,៦៨ លាននាក់**, បុគ្គល នៃវិស័យសាធារណៈ **៤៨ ម៉ឺននាក់**, និងបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុក របស់សមាជិក ប.ស.ស. ជាង **៣៦ ម៉ឺននាក់**។

២). **របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ** ក៏ត្រូវបានពង្រីកវិសាលភាព ដល់មន្ត្រីសាធារណៈ ដែលគិតត្រឹមឆ្នាំ២០២៤ របបសន្តិសុខសង្គមនេះមាន សមាជិកសកម្មចំនួន **១,៩៦ លាននាក់** ក្នុងនោះ កម្មករនិយោជិតចំនួន **១,៦៨ លាននាក់** និងមន្ត្រីសាធារណៈ ជាង **២៨ ម៉ឺននាក់** ដែលនិយោជកជា អ្នករ៉ាប់រងបង់ភាគទានទាំងស្រុង។

៣). **របបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់កម្មករនិយោជិត** បង្កើតឡើង និង ដាក់ឱ្យដំណើរការ កាលពីខែកក្កដា ឆ្នាំ២០២២ ដែលបច្ចុប្បន្ន គ្របដណ្តប់លើ

កម្មករនិយោជិតចំនួន **១,៦៨ លាននាក់** បន្ថែមពីលើរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដែលគ្របដណ្តប់និវត្តជនចំនួន **១២៩ ពាន់នាក់**។ រាជរដ្ឋាភិបាលគ្រោងចំណាយថវិកាចំនួន **១, ៥៤ ទ្រីលានរៀល** ឬសមមូលនឹង **៣៨៥ លានដុល្លារ** សម្រាប់បើកប្រាក់សោធនជូនអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ក្នុងឆ្នាំ២០២៤ នេះ។

*- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី!*
*- ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី!*

បន្ថែមលើកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ជាប្រក្រតីទាំងនេះ, នៅពេលកម្ពុជាជួបគ្រោះអាសន្នកន្លងមក ដែលរួមមានការរីករាលដាលនៃជំងឺកូវីដ-១៩, សម្ពាធអតិផរណា និងគ្រោះទឹកជំនន់ធ្ងន់ធ្ងរ, រាជរដ្ឋាភិបាលតែងគិតគូរជួយគាំពារពលរដ្ឋតាមរយៈការដាក់ចេញនូវអន្តរាគមន៍ពិសេសនានា ដើម្បីជួយរក្សាលំនឹងជីវភាព, កាត់បន្ថយកម្មវិបាកអវិជ្ជមាន និងស្តារជីវភាពរបស់ពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព តាមរយៈកម្មវិធីជំនួយសង្គមពិសេស ដូចខាងក្រោម៖

១). កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងប្រយុទ្ធនឹងជំងឺកូវីដ-១៩,
២). កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ទ្រង់ទ្រាយធំ,
៣). កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងមានសម្ពាធអតិផរណា, និង
៤). កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់។

ដើម្បីឱ្យជ្រាបកាន់តែច្បាស់ អំពីអន្តរាគន៍គាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នរបស់រាជរដ្ឋាភិបាល ដែលជួយពលរដ្ឋ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងគ្រោះអាសន្ននានា នាពេលកន្លងមក, ខ្ញុំសូមគោរពអញ្ជើញ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** គណៈអធិបតី និងអង្គពិធីទាំងមូល ទស្សនាវីដេអូឯកសារមួយដូចតទៅ។

***ដើម្បីទស្សនាវីដេអូឯកសារ(១០នាទី) សូមចុចតំណភ្ជាប់វីដេអូខាងក្រោម៖

https://t.me/socialprotectionkh/667

*- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*
*- ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី!*

តាមរយៈវីដេអូខ្លីនេះ, អង្គពិធីអាចនឹងឆ្ងល់ថា តើអន្តរាគមន៍គាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដែលបានចំណាយថវិកាជាតិដ៏ច្រើន ពិតជាបានជួយពលរដ្ឋប្រាកដមែនឬទេ?

ចម្លើយ គឺពិតជាបានជួយរក្សាលំនឹងជីវភាពគ្រួសារពលរដ្ឋគោលដៅពិតប្រាកដមែន ហើយថែមទាំងបានជួយដល់សេដ្ឋកិច្ចជាតិក្នុងកម្រិតម៉ាក្រូទៀតផង។

ការតាមដាន និងវាយតម្លៃជាបន្តបន្ទាប់ ដែលចាប់ផ្តើមតាំងពីសប្តាហ៍ទី៥ បន្ទាប់ពីការដាក់ឱ្យអនុវត្ត កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ រួមទាំងការវាយតម្លៃបន្ទាប់ពីអនុវត្តបានរយពេល១ឆ្នាំពេញ ដែលគាំទ្រដោយធនាគារពិភពលោក និងការវាយតម្លៃកម្មវិបាក (Impact Evaluation) នៃការអនុវត្តកម្មវិធីនេះ ក្នុងឆ្នាំ២០២១ ដែលបានធ្វើឡើងរួមគ្នារវាងក្រុមប្រឹក្សាជាតិគាំពារសង្គម និង UNDP និងការវាយតម្លៃតាមជុំ ជាបន្តបន្ទាប់ទៀតដោយឈរលើទិន្នន័យដែលប្រមូល និងវិភាគក្រុមអ្នកស្រាវជ្រាវឯករាជ្យ បានបង្ហាញថា កម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ បានផ្តល់ផលវិជ្ជមានជាច្រើន ដោយបានចូលរួមសម្រួលជីវភាពគ្រួសារក្រីក្រ និងងាយរងគ្រោះ ឱ្យរួចផុតពីការធ្លាក់ចូលទៅក្នុងបញ្ហាអសន្តិសុខស្បៀង, បំណុល, ការលក់ទ្រព្យសកម្មរបស់គ្រួសារ, បង្កើនប្រាក់សន្សំ និងសម្រួលបន្ទុកចំណាយរបស់គ្រួសារ ពិសេសចំណាយលើម្ហូបអាហារ, ថ្នាំសង្កូវ និងការអប់រំកូនចៅ។ លើសពីនេះ, កម្មវិធីនេះមានកម្មវិបាកលើម៉ាក្រូសេដ្ឋកិច្ចកម្ពុជាផងដែរ ដែលបានចូលរួមដល់កំណើនសេដ្ឋកិច្ចប្រមាណ ០,៥៥% ក្នុងឆ្នាំ២០២០ និង ០,៤៥% ក្នុងឆ្នាំ២០២១ ក៏ដូចជាបានរួមចំណែកក្នុងការកាត់បន្ថយអត្រានិកម្មភាពចំនួន ០,៥៧% ក្នុងឆ្នាំ២០២០ និង ០,៦២% ក្នុងឆ្នាំ២០២១ និងកាត់បន្ថយអត្រាភាពក្រីក្រក្នុងឆ្នាំ២០២០ និង ឆ្នាំ២០២១ ផងដែរ។ បន្ទាប់ពីកម្មវិធីបើកនាព្រឹកនេះ អង្គសន្និសីទជាតិក៏នឹងអាចស្វែងយល់តាមរយៈបទបង្ហាញអំពីលទ្ធផលនៃការវាយតម្លៃចុងគ្រានៃការអនុវត្តចំនួន២ទៀតដែលរួមមានទាំង ការវាយតម្លៃយន្តការអនុវត្ត Process Evaluation និងការវាយតម្លៃកម្មវិបាក Impact Evaluation។

បន្ថែមលើនេះ, ខណៈដែររាជរដ្ឋាភិបាលចំណាយថវិការដ្ឋចំនួន **២២៣ ប៊ីលានរៀល** ឬសមមូលនឹង **៥៥,៧ លានដុល្លារ** សម្រាប់ផ្ដល់ប្រាក់ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យចំនួនជិត **៥០ម៉ឺនគ្រួសារ** មានសមាជិក **១,៨ លាននាក់** ក្រោមកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់, ការវាយតម្លៃបានបង្ហាញថា គ្រួសារទទួលផលក្រោមកម្មវិធីទាំង ២ នេះ ប្រមាណ ៩៧% ពេញចិត្ត និងគាំទ្រអន្តរាគមន៍របស់រាជរដ្ឋាភិបាល ក្នុងទម្រង់ជាការឧបត្ថម្ភសាច់ប្រាក់ ដែលត្រូវបានប្រើប្រាស់ទៅលើមុខចំណាយចាំបាច់ ដូចជាម្ហូបអាហារ,សេវាសុខាភិបាល និងឱសថ, និងការសិក្សារបស់កូន ជាដើម។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ទាំង២ ក៏បានទប់ស្កាត់ការធ្លាក់ចុះធ្ងន់ធ្ងរនៃស្ថានភាពជីវភាពរបស់គ្រួសារគោលដៅ ដូចជា៖ ១). បានកាត់បន្ថយការកើនឡើងនៃអត្រាអសន្តិសុខស្បៀងក្នុងគ្រួសារចំនួន ១៣%, ២ ).បានជួយលើការសន្សំក្នុងគ្រួសារចំនួន ៧,៥%, ៣ ).បានជួយគ្រួសារឱ្យមានលទ្ធភាពបង់ថ្លៃសេវាទឹក-ភ្លើង, ថ្លៃជួលផ្ទះ, និងបង់ថ្លៃសេវាសុខាភិបាល ជាដើម។

ការវាយតម្លៃក៏បានបង្ហាញថាគ្រួសារពលរដ្ឋ ពិសេសគ្រួសារងាយរងហានិភ័យដែលទទួលបានសាច់ប្រាក់ឧបត្ថម្ភ មានទស្សនៈវិជ្ជមានលើរាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានដោយកម្មវិធីឧបត្ថម្ភសាច់ប្រាក់ទាំង ២ នេះ បានបង្កើនទស្សនៈវិជ្ជមានរបស់គ្រួសារគោលដៅមកលើរាជរដ្ឋាភិបាល ប្រមាណ ៣,៥% ធៀបនឹងពេលមុនអនុវត្តកម្មវិធីទាំងនេះ។

ជារួម ចាប់តាំងពីការចាប់ផ្ដើមអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦- ២០២៥, ប្រព័ន្ធគាំពារសង្គមកម្ពុជា ត្រូវបានពង្រីកវិសាលភាពធំជាងមុន ២ដងដែលបានកើនឡើងពីការគ្របដណ្ដប់ប្រជាពលរដ្ឋ **៣,៣ លាននាក់** កាលពីឆ្នាំ២០១៧ ដល់ជាង **៧លាននាក់** ក្នុងឆ្នាំ២០២៤ នេះ។

*- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី!*

*- ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី!*

សមិទ្ធផលដ៏ច្រើនទាំងនេះ បង្ហាញពីលទ្ធផលនៃកិច្ចសហការយ៉ាងជិតស្និត និងកិច្ចខិតខំរួមគ្នាពីសំណាក់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការចូលរួមជាជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល និងបណ្ដាញអង្គការសង្គមស៊ីវិលនានា។ ខ្ញុំសូមថ្លែងអំណរគុណគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!** ជាថ្មីម្តងទៀត ខ្ញុំសូមយកឱកាសនេះ សម្តែងនូវកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ចំពោះការចំណាយកម្លាំងកាយ និងកម្លាំងចិត្ត **បញ្ញាញាណ** ក្នុងការដឹកនាំតម្រង់ទិសការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ឱ្យសម្រេចបាននូវសមិទ្ធផលដ៏ច្រើនដូចបានបង្ហាញខាងលើ។

មុននឹងបញ្ចប់ ខ្ញុំសូមគោរពអរគុណយ៉ាងជ្រាលជ្រៅជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដែលបានផ្តល់កិត្តិយសអញ្ជើញចូលរួមជាអធិបតី ដ៏ខ្ពង់ខ្ពស់ ក្នុងសន្និសីទជាតិស្តីពីសមិទ្ធផលគាំពារសង្គមកម្ពុជា នៅថ្ងៃនេះ និងសូមគោរពជូនពរ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមសម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច និងប្រកបដោយសុខភាពល្អ ដើម្បីរួមគ្នាបន្តកសាងប្រព័ន្ធគាំពារសង្គមមួយដែលកាន់តែរឹងមាំ និងជវភាព សម្រាប់ព្រះរាជាណាចក្រកម្ពុជា។

ជាកិច្ចបន្ត, ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមអនុញ្ញាតគោរពអញ្ជើញ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាឡើងថ្លែងសុន្ទរកថា និងផ្តល់អនុសាសន៍ ជូនអង្គពិធីទាំងមូល។

**សូមគោរពអញ្ជើញ**!